ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ
THE STUDENT MOVEMENT FOR DEMOCRACY

លេខ៖ ០០០៦/២០ ច.ន.ប្រ.

រដ្ឋធានីវ៉ាស៊ីនតុន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

# សេចក្តីថ្លែងការណ៍
## ប្រទេសវៀតណាមត្រូវបញ្ឈប់ជាបន្ទាន់
## នូវអាជីវកម្ម-ពាណិជ្ជកម្ម និងការសាងសង់ទាំងអស់ នៅលើកោះត្រល់ និងចង្កោមកោះក្រចកសេះ

ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ សូមអំពាវនាវយ៉ាងទទូចដល់រដ្ឋាភិបាល និងរដ្ឋសភាកម្ពុជាបច្ចុប្បន្ន **(១)**-ត្រូវទាមទារ ឲ្យប្រទេសវៀតណាមបញ្ឈប់ជាបន្ទាន់នូវរាល់គម្រោង និងផែនការអាជីវកម្ម-ពាណិជ្ជកម្ម និងការសាងសង់ទាំងអស់ នៅលើកោះត្រល់ និងចង្កោមកោះក្រចកសេះ និង**(២)**-ត្រូវដាក់មោឃភាពជាផ្លូវការនូវច្បាប់ សន្ធិសញ្ញា កិច្ចព្រមព្រៀង និងឯកសារទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ឆ្នាំ១៩៩១។

កោះត្រល់ និងចង្កោមកោះក្រចកសេះ គឺជាទឹកដីកម្មសិទ្ធិរបស់ប្រទេសកម្ពុជា ដោយឈរលើមូលដ្ឋាន៖ **(១)**-សារាចរ លោក **Brévié** ឆ្នាំ១៩៣៩, **(២)**-អនុសញ្ញានៃអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រឆ្នាំ១៩៨២ **(៣)**-កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ឆ្នាំ១៩៩១, **(៤)**-រដ្ឋធម្មនុញ្ញជាច្បាប់កំពូល នៃព្រះរាជាណាចក្រកម្ពុជា, **(៥)**-ឯកសារផ្លូវការរបស់កម្ពុជា និង **(៦)**-ឯកសារច្បាប់ជាតិ-អន្តរជាតិ។ ប៉ុន្តែប្រទេសវៀតណាមបានឈ្លានពានកម្ពុជា ហើយដាក់សំពាធទៅលើកម្ពុជាក្នុងការប្រើប្រាស់ឯកសារខុសច្បាប់ ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិដែលមានជាធរមាន។

ខាងក្រោមនេះ គឺជាភស្តុតាងបង្ហាញឲ្យពិភពលោកបានឃើញជាក់ច្បាស់ថា ប្រទេសវៀតណាម និងប្រទេសកម្ពុជា បានរួមគ្នាប្រព្រឹត្តខុសច្បាប់៖

**១.** កំណត់ហេតុនៃការប្រជុំគ្នាលើកទី១ ពីថ្ងៃទី២២ ដល់២៧ ខែមិនា ឆ្នាំ១៩៩៩ គណៈកម្មាធិការចម្រុះព្រំដែនកម្ពុជា-វៀតណាម បានយកសន្ធិសញ្ញានិងកិច្ចព្រមព្រៀង ឆ្នាំ១៩៨២, ១៩៨៣ និងឆ្នាំ១៩៨៥ ទុកជាគោលការណ៍មូលដ្ឋាន សម្រាប់ដោះស្រាយបញ្ហាព្រំដែនរវាងប្រទេសទាំងពីរ។ រដ្ឋាភិបាលលោក **ហ៊ុន សែន** កាន់តែសម្រួលផ្លូវឲ្យវៀតណាមទន្ទ្រានទឹកដីកម្ពុជា តាមរយៈការប្រើប្រាស់សន្ធិសញ្ញាបំពេញបន្ថែម ឆ្នាំ២០០៥ និងឆ្នាំ២០១៩។

**២.** នៅក្នុងកិច្ចព្រមព្រៀងដែនទឹកប្រវត្តិសាស្រ្ត ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៨២ រវាងវៀតណាម-កម្ពុជា ភាគីវៀតណាមបានបញ្ចូលកោះត្រល់ និងចង្កោមកោះក្រចកសេះ ទៅក្នុងផែនទីទឹកដីប្រទេសវៀតណាម ដោយគ្មានសំអាងច្បាប់អ្វីទាំងអស់ ក្រៅតែពីប្រើពាក្យថា «យល់ឃើញសភាពការណ៍ជាក់ស្តែង» និងគ្រាន់តែយោងតាមសន្ធិសញ្ញាកម្ពុជា-វៀតណាម ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៩ ក្រោយពីកងទ័ពវៀតណាម ប្រើកម្លាំងចូលឈ្លានពានកាន់កាប់កម្ពុជាភ្លាមៗ។

**៣.** ការរំលោភទាំងស្រុង លើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីអំពីច្បាប់សមុទ្រឆ្នាំ១៩៨២។ ភាគីវៀតណាមមិនគោរពតាមអនុសញ្ញានេះ ដោយដណ្តើមកាន់កាប់កោះត្រល់ ចង្កោមកោះក្រចេះសេះ និងច្រកចេញចូលនាវាចរណ៍លើសមុទ្រអន្តរជាតិ ព្រមទាំងដែនអាកាសផង។

*អនុសញ្ញាស្តីអំពីច្បាប់សមុទ្រឆ្នាំ១៩៨២ ជំពូកទី២ ផ្នែក២ មាត្រា៣ ចែងថា «រាល់រដ្ឋទាំងអស់មានសិទ្ធិបង្កើតប្រវែង នៃដែនសមុទ្ររបស់ខ្លួនរហូតដល់ដែនកំណត់មិនលើសពី ចម្ងាយ ១២ ម៉ាយល៍ ស្មើនឹង ២២,២២៤ គីឡូម៉ែត្រ ដែលវាស់ពីខ្សែបន្ទាត់មូលដ្ឋាន ដែនកំណត់អនុលោមតាមអនុសញ្ញានេះ»។ តាមលក្ខខ័ណ្ឌភូមិសាស្រ្តជាក់ស្តែង កោះត្រល់មានរយៈចម្ងាយត្រឹមតែ ១៥ គីឡូម៉ែត្រ ពីខេត្តកំពត ប្រទេសកម្ពុជា ហើយ មានរយៈចម្ងាយ ៤៥ គីឡូម៉ែត្រ ពីតំបន់ហាទៀងនៃខេត្តកៀនយ៉ាង ប្រទេសវៀតណាម។*

**តាមច្បាប់សមុទ្រឆ្នាំ១៩៨២នេះ បញ្ជាក់យ៉ាងច្បាស់ថា កោះត្រល់គឺជាកម្មសិទ្ធិរបស់ខ្មែរ ដោយកោះនេះស្ថិតនៅចម្ងាយតែ ១៥ គីឡូម៉ែត្រ ពីឆ្នេរខេត្តកំពតនៃប្រទេសកម្ពុជា គឺតិចជាង២២,២២៤ គីឡូម៉ែត្រ ដែលកំណត់ដោយច្បាប់សមុទ្រនេះ។**

៤. ការរំលោភទាំងស្រុងទៅលើគោលការណ៍ ស្មារតី និងយន្តការរបស់អង្គការសហប្រជាជាតិ ដែលជាអាជ្ញាកណ្តាលដោះស្រាយវិបត្តិកម្ពុជា ហើយបានតាក់តែងឡើងនូវកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ឆ្នាំ១៩៩១ ដែលតម្រូវឲ្យប្រទេសកម្ពុជា និងប្រទេសវៀតណាមគោរព និងអនុវត្ត។

*សន្ធិសញ្ញា និងកិច្ចព្រមព្រៀង ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៩, ១៩៨២, ១៩៨៣ និង ឆ្នាំ១៩៨៥ រវាងវៀតណាម-កម្ពុជា នៅក្រោមការត្រួតត្រារបស់កងទ័ពវៀតណាម ត្រូវបានដាក់ជា «**មោឃភាព**» អស់ហើយ ដោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ ឯកសារទី២ នៃកិច្ចព្រមព្រៀងនេះ ក្នុងមាត្រា១ ត្រង់ចំណុច «២-ឃ.» ចែងថា៖ «បញ្ចប់សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយ ដែលមិនស្របអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដីអព្យាក្រឹតភាព និងឯកភាពជាតិរបស់ខ្លួន»។*

៥. ការរំលោភទាំងស្រុង លើគោលការណ៍អាស៊ាន (ASEAN) មានចែងក្នុងធម្មនុញ្ញអាស៊ាន ត្រង់មាត្រា២ ចំណុច២ ដែលចែងថា អាស៊ាន និងរដ្ឋសមាជិកត្រូវអនុវត្តឲ្យសមស្របតាមគោលការណ៍៖

*ក. គោរពឯករាជ្យភាព អធិបតេយ្យភាព សមភាព បូរណភាពទឹកដី និងអត្តសញ្ញាណជាតិនៃរដ្ឋសមាជិកអាស៊ានទាំងអស់។*

*ខ. ចូលរួមការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវរួមគ្នា ក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់។*

*គ. បដិសេធនូវ អំពើឈ្លានពាន និងការគំរាមគំហែង ឬការប្រើប្រាស់កំលាំង ឬសកម្មភាពទាំងឡាយណា ក្នុងលក្ខណៈដែលមិនសមស្របតាមច្បាប់អន្តរជាតិ។*

មាត្រា២ ដដែល ចំណុច១ ចែងថា៖

*រដ្ឋសមាជិករបស់ខ្លួនអះអាងជាថ្មី និងប្រកាន់ខ្ជាប់នូវគោលការណ៍ជាមូលដ្ឋានដូចចែងនៅក្នុងសេចក្តីថ្លែងការណ៍ កិច្ចព្រមព្រៀង អនុសញ្ញា សន្ធិសញ្ញា កិច្ចស្រុះស្រួល និងលិខិតូបករណ៍ដទៃទៀតរបស់អាស៊ាន។*

៦. ការរំលោភទាំងស្រុង លើរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៥៥ ចែងថា៖

*សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនស្រប នឹងឯករាជ្យ អធិបតេយ្យភាព បូរណភាពទឹកដី អព្យាក្រឹត្យភាព និងឯកភាពជាតិរបស់ប្រទេសកម្ពុជា ត្រូវលុបចោល។*

៧. រដ្ឋាភិបាលលោក **ហ៊ុន សែន** ខកខានប្រកាស «ដាក់មោឃភាព» ជាផ្លូវការ នូវសន្ធិសញ្ញា និងកិច្ចព្រមព្រៀងឆ្នាំ១៩៧៩ ១៩៨២ ១៩៨៣ និងឆ្នាំ១៩៨៥ ហើយអនុម័តសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ និងឆ្នាំ២០១៩ ដែលបានរំលោភទាំងខុសច្បាប់លើកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ឆ្នាំ១៩៩១ និងរដ្ឋធម្មនុញ្ញកម្ពុជា ត្រង់មាត្រា១៥០ ថ្មី (មាត្រា១៣១ ចាស់) ចែងថា៖

*ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។*

ទង្វើរំលោភបំពានទាំងខុសច្បាប់ ពីសំណាក់ប្រទេសវៀតណាម ក្នុងគោលបំណងលេបត្របាក់ទឹកដីកម្ពុជាដូចបានរៀបរាប់ខាងលើនេះ តម្រូវឲ្យយើងខ្ញុំជាម្ចាស់ប្រទេសវែកមុខភាគីដែដល់វៀតណាមប្រាប់ពិភពលោកថា កោះត្រល់ និងចង្កោមកោះក្រចកសេះ គឺជាកម្មសិទ្ធិរបស់ខ្មែរតាំងពីសម័យពុំទាន់មានកំណើតប្រទេសវៀតណាម រហូតមកដល់ពេលបច្ចុប្បន្ន និងទៅថ្ងៃអនាគត។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបស្តីពីឯកសារប្រវត្តិសាស្ត្រ ឯកសារផ្លូវការ និងឯកសារច្បាប់ជាតិ-អន្តរជាតិ តាមដំណើររឿងមិនដាច់សម័យកាល ដែលបញ្ជាក់ថា កោះត្រល់ និងចង្កោមកោះក្រចកសេះ គឺពិតជាកម្មសិទ្ធិរបស់ខ្មែរ៖

- លោក **Joseph Jules Brévié** អគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិន បានចេញសារាចរមួយទៅកាន់ទេសាភិបាលនៅកូសាំងស៊ីន (ឬកម្ពុជាក្រោមបច្ចុប្បន្ន) ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៣៩ បញ្ជាក់លំអិតថា *«តាមលក្ខខណ្ឌភូមិសាស្ត្រជាក់ស្តែង ជាការចាំបាច់ ត្រូវតែដាក់កោះទាំងនេះ ឲ្យនៅក្រោមការគ្រប់គ្រង នៃរាជការប្រទេសកម្ពុជា»*។ សារាចរនេះបន្ថែមថា *«ដែនកូសាំងស៊ីនរបស់បារាំងបានគ្រប់គ្រងលើកោះត្រល់ និងចង្កោមកោះមួយចំនួន តែផ្នែកប៉ូលីស និងរដ្ឋបាលប៉ុណ្ណោះ»*។ ទោះបីជាបារាំង បានប្រគល់កូសាំងស៊ីន ឲ្យអណ្ណាម (វៀតណាមសព្វថ្ងៃ) ត្រួតត្រា កាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៤៩ ក៏ដោយ ក៏មិនបានភ្ជាប់កោះត្រល់ ទៅជាមួយឡើយ។ ម្យ៉ាងទៀត ខ្មែរពេលនោះ គឺជាសមាគតរដ្ឋ (État Associé) ដែលស្ម័គ្រចិត្តចូលក្នុងសហភាពបារាំង (L'union française)។ កាលនោះ ឈ្មោះប្រទេសវៀតណាម មិនទាន់មានទេ គឺមានតែឈ្មោះ អណ្ណាម។

- នៅឯសន្និសីទក្រុងហ្សឺណែវ ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៥៤ ស្តីអំពីការបញ្ចប់សង្គ្រាមឥណ្ឌូចិនទី១ ប្រទេសកម្ពុជា នៅតែបានបន្តតវ៉ាប្រឆាំងនឹងការផ្ទេរដោយមិនស្មើភាពគ្នា និងអយុត្តិធម៌ នៃទឹកដីកូសាំងស៊ីនរបស់ខ្លួនទៅឲ្យអណ្ណាមដោយបារាំង។ កម្ពុជាបានសង្កត់បង្ហាញអំពីការរក្សាសិទ្ធិ ដើម្បី

ប្តឹងជំទាស់ករណីនេះ ទៅអង្គការសហប្រជាជាតិ និងរក្សាសិទ្ធិជាម្ចាស់កម្មសិទ្ធិ លើកោះនានា នៅតាមបណ្តោយឈូងសមុទ្រសៀម រួមមានកោះត្រល់ដែរ។

- លោក **ជូ អេនឡាយ** អតីតនាយករដ្ឋមន្ត្រីចិន និងលោក **ចេន យី** អតីតសេនាប្រមុខចិន ដែលជាវីរបុរសចំណាស់ ជាមួយលោកប្រធាន **ម៉ៅ សេទុង** នៃប្រទេសចិន ធ្លាប់បានមានប្រសាសន៍ទូលថ្វាយអង្គសម្តេចឪ **នរោត្តម សីហនុ** នាអំឡុងឆ្នាំ១៩៥៥ ថា «ច្បាស់ណាស់ កោះត្រល់ជារបស់ខ្មែរ ត្បិតជាប់នឹងទឹកដីខ្មែរ មិនជាប់ជាមួយទឹកដីវៀតណាមទេ»។

- លិខិតរបស់សម្តេចព្រះ **នរោត្តម សីហនុ** ជានាយករដ្ឋមន្ត្រី ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ១៩៥៧ បញ្ជាក់ច្បាស់ថា «កងនាវាចរខេមរភូមិន្ទ ការពារកោះនានានៅឈូងសមុទ្រសៀម ជាពិសេសនៅលើកោះអាចម៍សេះ កោះតាំង និងកោះក្រចកសេះ»។

- ព្រះរាជក្រឹត្យលេខ ៦៦២-ន.ស ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៥៧ ប្រកាសដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះបាទ **នរោត្តម សុរាម្រឹត** ក្នុងប្រការ៦ និងប្រការ៧ បញ្ជាក់ថា «កោះត្រល់ ឬកោះភូកុក ជាឈ្មោះតែមួយ ជាកោះដែលនៅក្នុងដែនអធិបតេយ្យភាពខ្មែរយ៉ាងជ្រៅ។ គ្មានជំនាន់ណាហ៊ានកាត់ទៅឲ្យយួននោះទេ»។

- អនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីអំពី «ច្បាប់សមុទ្រ» នៅទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៨ ត្រង់មាត្រាទី២ ចំណុច១ ចែងថា៖

  *«រដ្ឋដែលជាប់ឆ្នេរសមុទ្រ អនុវត្តន៍លើសិទ្ធិអធិបតេយ្យភាពនៃខ្ពង់សមុទ្រ (ឬខ្ពង់រាបបាតសមុទ្រ) សម្រាប់គោលបំណង រុករក និងធ្វើអាជីវកម្ម លើប្រភពធនធានធម្មជាតិនៅតំបន់នោះ»។*

- ក្នុងសៀវភៅភូមិសាស្ត្រកម្ពុជា «Cambodia Geography» បោះពុម្ពក្នុងឆ្នាំ១៩៦៣ ដោយលោក **តាន់ គីមហួន** (Tan Kim Huon) ជារុក្ខក្សេត្រវិទូ បានចង្អុលបង្ហាញថា កោះត្រល់ពិតជាកោះមួយរបស់កម្ពុជា (យោងតាម ផែនទីលេខ៣, ១២ និងលេខ ១៩)។

- នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៦៨ សម្តេចព្រះ **នរោត្តម សីហនុ** បានឡាយព្រះហស្ថលេខាលេខ ៣៧៨/៦៨CE ស្តីអំពីអនុសញ្ញា «ខ្ពង់រាបបាតសមុទ្រ»។ តាមអនុសញ្ញានេះ កោះត្រល់ និងចង្កោមកោះក្រចកសេះ គឺជាកម្មសិទ្ធិរបស់ប្រទេសកម្ពុជា។

- ឆ្នាំ១៩៦៩ កោះត្រល់ ត្រូវបានបញ្ចូលក្នុងបញ្ជីឈ្មោះជាផ្លូវការ នៃកោះទាំងអស់របស់ខ្មែរ។ កោះត្រល់នៅក្នុងលេខរៀងទី៦១ ក្នុងបញ្ជីនៃកោះខ្មែរទាំង ៦៤។

- ថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៧២ ស្ថានទូតសហរដ្ឋអាមេរិកប្រចាំទីក្រុងភ្នំពេញ បានផ្ញើសារ តាមប្រព័ន្ធ AIRGRAM ទៅកាន់ក្រសួងការបរទេសសហរដ្ឋអាមេរិក ស្តីអំពីច្បាប់សមុទ្រ «កម្ពុជាកំណត់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួន»។ នៅក្នុងសារនោះបានបញ្ជាក់យ៉ាងច្បាស់ថា កោះត្រល់ស្ថិតនៅក្នុងដែនសមុទ្ររបស់កម្ពុជា។

- ផែនទីខ្មែរ ឆ្នាំ១៩៥៤-១៩៧៣ ដែលត្រូវបានប្រើដោយសន្និសីទក្រុងប៉ារីស ស្តីអំពីការបញ្ចប់សង្គ្រាមឥណ្ឌូចិន លើកទី២ ខែសីហា ឆ្នាំ១៩៧៣ មានឃើញកោះត្រល់ក្នុងដែនទឹកដីរបស់ប្រទេសកម្ពុជា។ តំណាងវៀតណាម ដែលមានវត្តមានក្នុងសន្និសីទនោះ ក៏មិនបានតវ៉ាដែរ។

- រដ្ឋាភិបាលសម័យសាធារណរដ្ឋខ្មែរ លោក **លន់ នល់** និងរបបកម្ពុជាប្រជាធិបតេយ្យ (ឬខ្មែរក្រហម) ក៏បញ្ជាក់ថា «កោះត្រល់ គឺជាកម្មសិទ្ធិរបស់កម្ពុជា»។ តាមក្រឹត្យច្បាប់ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៧២ រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ បានរក្សាការអះអាងជាថ្មីនូវអធិបតេយ្យភាពទឹកដីរបស់ខ្លួន លើខ្ពង់សមុទ្រ (ឬខ្ពង់រាបបាតសមុទ្រ)។ នៅឆ្នាំ១៩៧៦ កងទ័ពខ្មែរក្រហម ក៏បានឈររជើងនៅលើកោះត្រល់ផងដែរ។

- សៀវភៅមុខវិជ្ជាភូមិវិទ្យា សម្រាប់សិស្សានុសិស្សថ្នាក់ទី៧ ឆ្នាំ១៩៨៥ បោះពុម្ពដោយក្រសួងអប់រំ នៃរបបធារណរដ្ឋប្រជាមានិតកម្ពុជា ក្រោមការត្រួតត្រារបស់កងទ័ពវៀតណាមឈ្លានពាន បានសរសេរថា កោះត្រល់ ស្ថិតក្នុងក្រុមទី៣ នៅក្នុងចំណោមចង្កោមកោះទាំងអស់របស់កម្ពុជា។

- ប្រទេសសិង្ហបុរី បានបញ្ជូនសេចក្តីរាយការណ៍ទៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៨៦ ថា «កិច្ចព្រមព្រៀងរវាងកម្ពុជា-វៀតណាម ឆ្នាំ១៩៨២ ស្តីអំពីដែនទឹកប្រវត្តិសាស្ត្រ» ត្រូវបានបង្ខំឲ្យចុះហត្ថលេខាដោយវៀតណាម នៅពេលវៀតណាមចូលឈ្លានពានត្រួតត្រាប្រទេសកម្ពុជា ចាប់តាំងពីចុង ឆ្នាំ១៩៧៨ មក ហើយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា នាពេលនោះ មិនមែនជាតំណាងស្របច្បាប់របស់ប្រទេស ឬតំណាងផលប្រយោជន៍ឲ្យពលរដ្ឋខ្មែរទេ គឺមានតែរដ្ឋាភិបាលចម្រុះត្រីភាគី នៃសម្តេចព្រះ **នរោត្តម សីហនុ** តែមួយគត់ ដែលត្រូវបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិ។

- រដ្ឋាភិបាលសហរដ្ឋអាមេរិក នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៨៧ បានធ្វើការប្រឆាំងជំទាស់នឹងកិច្ចព្រមព្រៀងកម្ពុជា-វៀតណាម ឆ្នាំ១៩៨២ ស្ដីអំពីដែនទឹកប្រវត្តិសាស្ត្រនេះ។ ប្រទេសសិង្ហបុរី ប្រទេសថៃ និងប្រទេសអាល្លឺម៉ង់ ក៏បានចូលរួមជាមួយសហរដ្ឋអាមេរិក ក្នុងការប្រឆាំងជំទាស់នឹងកិច្ចព្រមព្រៀងដែនទឹកប្រវត្តិសាស្ត្រនេះដែរ។ ក្នុងកិច្ចព្រមព្រៀងដែនទឹកប្រវត្តិសាស្ត្រនេះ ប្រទេសវៀតណាមបានកាត់ឆ្វៀលយកកោះត្រល់ ចង្កោមកោះក្រចកសេះ គ្រប់គ្រងដែនអាកាស ព្រមទាំងដាក់ផ្ទៃសមុទ្រទំហំ ១០.០០០ (១ម៉ឺន) គីឡូម៉ែត្រក្រឡា ដែលកម្មសិទ្ធិរបស់កម្ពុជាឲ្យទៅជាដែនទឹករួមគ្នាជាមួយវៀតណាម ។

- ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩ អតីតព្រះមហាក្សត្រ ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** បានរំឭកលោក **ហ៊ុន សែន** ជាប្រមុខរដ្ឋាភិបាលថា «គ្មានសម័យណា គ្មានមេដឹកនាំណា ដែលហ៊ាននិយាយថា កោះត្រល់ ត្រូវបានកាត់ទៅឲ្យវៀតណាមទេ»។ ព្រះអង្គមានព្រះបន្ទូល ថា *«កោះត្រល់ ជារបស់កម្ពុជា»*។

ខាងលើនេះ គឺជាភស្តុតាងផ្លូវច្បាប់ជាមូលដ្ឋាន ដើម្បីបង្កើតនូវសាលក្រមកាត់សេចក្ដីថា វៀតណាម គឺជាចារី (ភាគីដៃដល់) ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ក្នុងការលេបត្របាក់ទឹកដីខ្មែរដោយមិនអាចប្រកែកបាន។ ទោះបីខ្លួនជាសមាជិកអង្គការសហប្រជាជាតិ ជាសមាជិកអាស៊ាន និងជាប្រទេសហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ក៏ដោយ វៀតណាមនៅតែបន្តធ្វើសកម្មភាពឈ្លានពានកម្ពុជាជាបន្តបន្ទាប់ ដោយឥតអៀនខ្មាស ជាពិសេស ពេលថ្មីៗនេះវៀតណាមបានមកបោះជំរំយ៉ាងតិចចំនួន២៥៦កន្លែង នៅលើទឹកដីកម្ពុជា និងបន្តបង្ហូរជនជាតិវៀតណាមខុសច្បាប់រាប់លាននាក់ មករស់នៅលើទឹកដីកម្ពុជា។ ការឈ្លានពានកម្ពុជា ពីសំណាក់ប្រទេសវៀតណាម នឹងនាំមកនូវគ្រោះមហន្តរាយដល់អាយុជីវិតទឹកដីជាតិកម្ពុជាទាំងមូល និងក៏ជាការគំរាមកំហែងដល់ស្ថិរភាព និងសន្តិភាពនៃប្រជាជាតិអាស៊ានដែរ។ ប្រទេសវៀតណាម ត្រូវទទួលខុសត្រូវនៅចំពោះមុខច្បាប់អន្តរជាតិ នូវរាល់ទង្វើឈ្លានពានរបស់ខ្លួនមកលើទឹកដីប្រទេសកម្ពុជា។

កម្ពុជាខ្លួនឯងត្រូវឈានមុខក្នុងការការពារ អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ខ្លួន។ ចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ សូមអំពាវនាវជាថ្មីដល់រដ្ឋាភិបាល និងរដ្ឋសភាកម្ពុជាបច្ចុប្បន្ន **(១)**-ត្រូវទាមទារឲ្យប្រទេសវៀតណាម បញ្ឈប់ជាបន្ទាន់ នូវរាល់គម្រោង និងផែនការ អាជីវកម្ម-ពាណិជ្ជកម្ម និងការសាងសង់ទាំងអស់ នៅលើកោះត្រល់ និងចង្កោមកោះក្រចកសេះ និង **(២)**-ត្រូវដាក់មោឃភាព ជាផ្លូវការនូវច្បាប់ សន្ធិសញ្ញា កិច្ចព្រមព្រៀង និងឯកសារទាំងឡាយណាដែលផ្ទុយពីខ្លឹមសារនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ឆ្នាំ១៩៩១៕

**ប្រធានប្រតិបត្តិ**

**ទូច វិបុល**